

## គម្រោង៖
# ពង្រឹងសមត្ថភាពអង្គការសង្គមស៊ីវិលដើម្បីសិទ្ធិកុមារ

## គោលដៅគម្រោង៖

- អង្គការសង្គមស៊ីវិល និងបណ្តាញនានាបានពង្រឹងសមត្ថភាពបច្ចេកទេស និងប្រតិបត្តិការ ដើម្បីបំពេញបេសកកម្មរបស់ពួកគេក្នុងការការពារសិទ្ធិកុមារនៅកម្ពុជា។
- កុមារា កុមារី  និងកុមារដែលមាននិន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញទំនោរយេនឌ័រផ្សេងទៀត បានចូលរួមក្នុងការតស៊ូមតិដែលដឹកនាំដោយកុមារ និងយុវជន និងយុទ្ធនាការនានាដើម្បីជះឥទ្ធិពលដល់មិត្តភ័ក្តិ សហគមន៍ និងអ្នកធ្វើសេចក្តីសម្រេចចិត្ត ដើម្បីលើកកម្ពស់សិទ្ធិកុមារនៅកម្ពុជា។
- អង្គការសង្គមស៊ីវិល និងបណ្តាញនានា ធ្វើការការពារសិទ្ធិកុមារ ដោយធ្វើយ៉ាងណាឲ្យរាជរដ្ឋាភិបាលកម្ពុជា ទទួលខុសត្រូវចំពោះកាតព្វកិច្ចរបស់ខ្លួនក្នុងការផ្តល់លទ្ធភាពទទួលបានប្រព័ន្ធការពារដែលមានបរិយាបន្ន និងសេវាកម្មដែលមានគុណភាពដល់កុមារ រួមទាំងអ្នកដែលងាយរងគ្រោះ ប្រកបដោយវិសមភាព និងគ្មានការរើសអើង។
- អង្គការសង្គ្រោះកុមាររួមជាមួយអង្គការសង្គមស៊ីវិលកម្ពុជារួមគ្នាដើម្បីការពារសង្គមស៊ីវិល កិច្ចសន្ទនា កុមារ និងយុវជន ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងថ្នាក់មូលដ្ឋាន។


## ទំនាក់ទំនងមកអង្គការ

០២៣ ៨៨២ ៤១២

info@crc-cambodia.org


## តើគួរផ្តល់មតិយោបល់ទៅលើគម្រោងតាមរបៀបណា?

- ប្រអប់ផ្តល់មតិយោបល់ផ្ទាល់នៅមុខការិយាល័យអង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជា ស្ថិតនៅអាសយដ្ឋាន ផ្ទះលេខ ៨អា ផ្លូវ ១៣៨ សង្កាត់វាល់វង់ ខណ្ឌ ៧ មករា រាជធានីភ្នំពេញ
- ការផ្តល់មតិយោបល់ផ្ទាល់មាត់នៅក្នុងការប្រជុំ វគ្គបណ្តុះបណ្តាល ឬកម្មវិធីផ្សេងៗ

## រយៈពេលអនុវត្តគម្រោង៖
ចាប់ពីថ្ងៃទី ០១ ខែសីហា ឆ្នាំ២០២២ ដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២៦ (៥ឆ្នាំ)



## ម្ចាស់ជំនួយ៖
ភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍអន្តរជាតិស៊ុយអែត (Sweden Sverige)

Sweden Sverige
Save the Children

## ថវិកាអនុវត្តគម្រោង៖
៣៧៥.០០០ ដុល្លារសហរដ្ឋអាមេរិក

## អំពីអង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជា (ស.ស.ក)

អង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជា (ស.ស.ក) បានបង្កើតឡើងក្នុងឆ្នាំ ១៩៩៤ ជាសម្ព័ន្ធនៃអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដែលធ្វើការផ្តោតលើសិទ្ធិកុមារ។ ស.ស.ក ធ្វើការនៅក្នុងប្រទេសកម្ពុជាដើម្បីលើកកម្ពស់ និងការពារសិទ្ធិកុមារ រួមទាំងការតស៊ូមតិ និងធានាបាននូវការគាំទ្រសម្រាប់ការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារតាមរយៈការលើកកម្ពស់ការយល់ដឹង ការត្រួតពិនិត្យការអនុវត្ត និងកិច្ចសហប្រតិបត្តិការជាមួយអង្គការសមាជិក បណ្តាញ និងអ្នកពាក់ព័ន្ធនានា។

### ទស្សនៈវិស័យ៖

កុមារគ្រប់រូបទទួលបានសិទ្ធិ ហើយអាចប្រើប្រាស់សិទ្ធិរបស់ខ្លួនប្រកដោយសេចក្តីថ្លៃថ្នូរ និងឈានដល់ការសម្រេចសក្តានុពលពេញលេញ។

### បេសកកម្ម៖

សម្រេចឱ្យបាននូវសិទ្ធិកុមារតាមរយៈការជម្រុញការទទួលខុសត្រូវរបស់អ្នកមាន កាតព្វកិច្ចក្នុងការអនុវត្ត ការប្តេជ្ញាចិត្តផ្នែកគោលនយោបាយ និងបង្កើតការវិនិយោគដើម្បីគោរព ការពារ និងបំពេញសិទ្ធិរបស់កុមារឱ្យកាន់តែល្អប្រសើរ។

### គុណតម្លៃ៖

ប្តេជ្ញាលើកកម្ពស់សិទ្ធិរបស់កុមារតាមរយៈធ្វើឱ្យមានគុណតម្លៃនេះ៖

- គណនេយ្យភាព
- ការគោរពគ្នាទៅវិញទៅមក
- កិច្ចសហប្រតិបត្តិការ
- តម្លាភាព និងការមិនរើសអើង។



## ក្រុមគោលដៅ

- ថ្នាក់ជាតិ៖ ក្រសួង និងស្ថាប័នពាក់ព័ន្ធនានា
- អង្គការសមាជិកនៃ ស.ស.ក
- បណ្តាញដែលដឹកនាំដោយកុមារ និងយុវជន (បណ្តាញអ្នកតស៊ូមតិ, ក្រុមតំណាងយុវវ័យ និងយុវជន, សមាគមចលនាកុមារ និងយុវជនកម្ពុជាដើម្បីសិទ្ធិកុមារ)



## ព័ត៌មានគណនេយ្យភាព៖

- ការផ្តល់មតិយោបល់របស់លោកអ្នក និងប្អូនៗកុមារ និងយុវជនមានសារៈសំខាន់ណាស់ក្នុងការធ្វើឲ្យគម្រោងរបស់យើងកាន់តែមានប្រសិទ្ធិភាព។
- ការផ្តល់យោបល់របស់អ្នក និងប្អូនៗទាំងអស់នឹងត្រូវបានអង្គការរក្សាជាសម្ងាត់ និងធ្វើការអភិវឌ្ឍគម្រោងឲ្យកាន់តែល្អប្រសើរ។

## អង្គការដៃគូ និងបណ្តាញ៖

អង្គការដៃគូ និងបណ្តាញ៖

- អង្គការសង្គ្រោះកុមារកម្ពុជា
- អង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជា
- សមាគមចលនាកុមារ និងយុវជនកម្ពុជាដើម្បីសិទ្ធិកុមារ
- អង្គការ Live & Learn Cambodia
- អង្គការគណៈកម្មាធិកាសហប្រតិបត្តិការដើម្បីកម្ពុជា
- អង្គការនារីអភិវឌ្ឍន៍សេដ្ឋកិច្ច និងអនាម័យ
- អង្គការតំណាងជនពិការ និងវេទិកាស្ត្រី និងកុមារមានពិការភាព
- អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា



## SIDA CSO Strengthening Project

### About us

Child Rights Coalition Cambodia (CRC-Cambodia), formerly the NGO Coalition on the Rights of the Child (NGOCRC), was founded in 1994 as an alliance of national and international non-governmental organizations focused on child rights. The coalition has a long history of working in Cambodia to promote and protect children´s rights, including advocating and ensuring support for the Convention on the Rights of the Child (CRC) through awareness-raising, monitoring its implementation, cooperating with member organizations, and networking with relevant agencies.

### Visoin

"Every child freely enjoys and exercises their rights with dignity, and reaches their full potential".

### Mission

To realize the rights of children through upholding the accountability of duty-bearers to implement policy commitments and increase investments to respect, protect, and fulfill the rights of children.

### Value

To commit to promoting children´s rights through the value of accountability, mutual respect, cooperation, transparency, and non-discrimination.

### Project's goals

- Child rights CSOs and networks have strengthened their technical and operational capacities to fulfill their mission in defending child rights in Cambodia.
- Girls, boys, and children with diverse SOGIE engage in child-led advocacy and campaigning to influence peers, communities and decision makers to promote child rights in Cambodia.
- CSOs and networks defend children's rights by holding the RCG accountable for its obligation in providing access to inclusive systems and quality services to children, including the most impacted by inequality and discrimination.
- Save the Children together with Cambodian civil society's CSOs join forces to safeguard CSO, children and youth civic dialogue at grassroots, sub-national and national level.

### Target Beneficiary

- National Level: Relevant key Ministries and Organization
- CSO Members
- Child and Youth-Led Networks (Child Advocate Network, Adolescent and Youth Reference Group, and Cambodia Children and Young People Movement for Child Rights)



### Contact to our organization

023 88 24 12

info@crc-cambodia.org

### How can you provide the feedback to the project?

Feedback box Infront of CRC-Cambodia´s office located in #8A Street 138 Sangkat Veal Vong Khan 7 Makara, Phnom Penh, Cambodia.

Giving feedback at meetings, trainings or other programs.

### Project Implementation Period

1st August 2022 to 31st December 2026 (5 Years)



### Donor

Swedish International Development Cooperation Agency (SIDA)

Sweden Sverige

Save the Children

### Total Budget for 5 years

USD 375,000

### Accountability Mechanism

- Your feedback is very important to make our project more effective.
- Your suggestions will be kept confidential and the project will be better developed.

### CSO Partners and Networks

- Save the Children (SCI)
- Child Righs Coalition Cambodia (CRC-Cambodia)
- Cambodia Children and YOung Poeple Movement for Child Rights (CCYMCR)
- Live & Learn Cambodia
- Cooperation Committee for Cambodia (CCC)
- Women Organization for Modern Economy and Nursing (WOMEN)
- Gender and Development for Cambodia (GADC)
- Cambodian Disabled People´s Organization (CDPO)

